# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## អនុស្សរណៈនៃការយោគយល់គ្នា
## ស្តីពី
## ការប្រើប្រាស់សេវាកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី
## សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

អនុស្សរណៈនេះត្រូវបានរៀបចំឡើងនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០១២ រវាង ៖

លោក **អ៊ិន ចាន់នី** ជាប្រធាននាយកប្រតិបត្តិធនាគារ **អេស៊ីលីដា ភីអិលស៊ី** ដែលមានទីស្នាក់ការកណ្តាល ស្ថិតនៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ហៅកាត់ថា ភាគី"ក" ។

**និង**

ឯកឧត្តម **សរ ចំរុង** ជាអភិបាលខេត្តក្រចេះ តំណាងឲ្យលោក **លោកស្រីមេឃុំ ចៅសង្កាត់** (ម្ចាស់គម្រោង) នៅខេត្តសាមី ហៅកាត់ថា ភាគី"ខ" ។

## <u>ភាគីទាំងពីរបានព្រមព្រៀងគ្នា ដូចខាងក្រោម</u> ៖

### ប្រការ ១ ៖ អំពីសេវាកម្ម

១.១. ភាគី"ខ" យល់ព្រមណែនាំដល់**អ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម** និង**អ្នកផ្គត់ផ្គង់ទំនិញ**ឲ្យមកប្រើប្រាស់សេវាកម្មលិខិតធានាការដេញថ្លៃ និងលិខិតធានាប្រាក់កក់ធានាការអនុវត្តរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

១.២. ភាគី"ក" យល់ព្រមផ្តល់នូវសេវាកម្មធនាគារភាគី"ខ" ដូចបានរៀបរាប់ក្នុងចំណុច១.១ខាងលើ ។

### ប្រការ ២ ៖ ការចេញលិខិតធានា និងកម្រៃសេវាកម្ម

២.១. ភាគី"ក" យល់ព្រមចេញលិខិតធានាជូនអ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញទៅតាមទម្រង់គំរូរបស់ម្ចាស់គម្រោងចំនួន០៤ច្បាប់ ដែលក្នុងនោះ ច្បាប់ដើមចំនួន០១ច្បាប់ និងច្បាប់ថតចម្លងចំនួន០២ច្បាប់ផ្តល់ជូនទៅអ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញ និងច្បាប់ថតចម្លងចំនួន០១ច្បាប់ទៀត រក្សាទុកនៅភាគី"ក" ។

២.២. ភាគី"ក" នឹងគិតកម្រៃសេវាក្នុងការចេញលិខិតធានាប្រាក់កក់ពីអ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញក្នុងការតម្កល់សាច់ប្រាក់ធានា នៅភាគី"ក" ក្នុងអត្រាដោយគណនាតាមរូបមន្ត ៖ **ថ្លៃសេវាត្រូវបង់ = ចំនួនប្រាក់កក់ x អត្រា(0,0៨%) x រយៈពេលធានា(គិតជាខែ)** ឬ **ថ្លៃសេវាអប្បបរិមាចំនួន៦(ប្រាំមួយ)**ដុល្លារសហរដ្ឋអាមេរិក សម្រាប់ប្រតិបត្តិការចេញលិខិតធានា ០១លើកៗ ។

២.៣. ភាគី"ក" នឹងមិនគិតកម្រៃសេវាក្នុងការផ្ទេរបង្វែរសាច់ប្រាក់ក្នុងលិខិតធានា ទៅក្នុងគណនីរបស់ម្ចាស់គម្រោង តាមការស្នើសុំរបស់ម្ចាស់គម្រោង ។

### ប្រការ ៣ ៖ ការផ្ទេរបង្វែរសាច់ប្រាក់ក្នុងលិខិតធានា

៣.១. ក្នុងករណីម្ចាស់គម្រោងត្រូវការរឹបអូសសាច់ប្រាក់ក្នុងលិខិតធានា ម្ចាស់គម្រោងត្រូវធ្វើលិខិតស្នើសុំផ្ទេរបង្វែរសាច់ប្រាក់ជាលាយល័ក្ខណ៍អក្សរមកកាន់ភាគី"ក"សាមីដែលចេញលិខិតធានា ដោយបញ្ជាក់អំពីមូលហេតុឲ្យបានច្បាស់លាស់នៃការមិនបានអនុវត្តតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងឯកសារដេញថ្លៃ

Ch

ឬកិច្ចសន្យារបស់អ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម និងអ្នកផ្គត់ផ្គង់ទំនិញ ស្របតាមល័ក្ខខ័ណ្ឌនៃលិខិតធានា នៅក្នុងអំឡុងពេលសុពលភាពនៃលិខិតធានា ។

៣.២. ករណីពិសេស **ម្ចាស់គម្រោង**អាចបញ្ជូនលិខិតស្នើសុំផ្ទេរបង្វែរសាច់ប្រាក់ក្នុងលិខិតធានា ទៅបណ្តាសាខាណាមួយរបស់ភាគី"ក"បាន ដើម្បីជួយធ្វើការបញ្ជូនបន្តទៅកាន់សាខាសាមី ដែលបានចេញលិខិតធានា ។

៣.៣. ភាគី"ក" នឹងផ្ទេរបង្វែរសាច់ប្រាក់ក្នុងលិខិតធានា ជូនទៅម្ចាស់គម្រោង ក្រោយពីបានទទួលលិខិតស្នើសុំផ្ទេរបង្វែរសាច់ប្រាក់ ដែលត្រឹមត្រូវតាមល័ក្ខខ័ណ្ឌនៃលិខិតធានា មិនលើសពី**០៥ថ្ងៃធ្វើការ** បន្ទាប់ពីបានទទួលលិខិតស្នើសុំនោះ ។

៣.៤. ភាគី"ក" មិនទទួលខុសត្រូវចំពោះបញ្ហាណាមួយដែលកើតឡើងពាក់ព័ន្ធនឹងការផ្ទេរបង្វែរសាច់ប្រាក់ក្នុងលិខិតធានា ចូលជាថវិការដ្ឋ ដូចមានចែងក្នុងចំណុច៣.១ និង៣.២ខាងលើឡើយ ។

៣.៥. ភាគី"ខ" ព្រមព្រៀងដោះស្រាយបញ្ហាដោយផ្ទាល់ចំពោះមុខច្បាប់ ជាមួយអ្នកដេញថ្លៃ អ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ទំនិញ ករណីមានការតវ៉ាទាមទារណាមួយដែលកើតឡើង ទាក់ទងនឹងការផ្ទេរបង្វែរប្រាក់ចូលជាថវិការដ្ឋ ដែលភាគី"ក"បានអនុវត្តតាមលិខិតស្នើសុំរបស់ម្ចាស់គម្រោង ។

**ប្រការ ៤ ៖ សុពលភាព ការកែប្រែ និងការបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នា**

៤.១. អនុស្សរណៈនៃការយោគយល់គ្នានេះមានប្រសិទ្ធភាពអនុវត្តគិតចាប់ពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ។

៤.២. ភាគីទាំងពីរអាចធ្វើការត្រួតពិនិត្យ ឬកែប្រែអនុស្សរណៈនៃការយោគយល់គ្នានេះ តាមតម្រូវការចាំបាច់ ដោយមានការព្រមព្រៀងគ្នាជាលាយល័ក្ខណ៍អក្សរពីភាគីទាំងពីរ ។

៤.៣. ភាគីនីមួយៗអាចធ្វើការបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នានេះមុនកាលកំណត់បាន លុះត្រាតែមានការព្រមព្រៀងគ្នាជាលាយល័ក្ខណ៍អក្សររវាងភាគីទាំងពីរជាមុន ។

**ប្រការ ៥ ៖ ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា និងការដោះស្រាយវិវាទ**

៥.១. អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវអនុវត្តស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ នៅពេលមានវិវាទកើតឡើង ភាគី"ក" និងភាគី"ខ" ព្រមព្រៀងគ្នាដោះស្រាយដោយសន្តិវិធី ។ ក្នុងករណីមិនអាចផ្សះផ្សាគ្នាបាន ភាគីទាំងពីរត្រូវដោះស្រាយវិវាទតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

៥.២. រាល់ការចំណាយផ្សេងៗដែលកើតឡើងទាក់ទងនឹងការដោះស្រាយវិវាទនេះ គឺជាបន្ទុករបស់ភាគីដែលរំលោភលើអនុស្សរណៈនៃការយោគយល់គ្នានេះ ។

៥.៣. អនុស្សរណៈនៃការយោគយល់គ្នានេះធ្វើឡើងជាភាសាខ្មែរ ចំនួន០២(ពីរ)ច្បាប់ ដោយរក្សាទុកនៅភាគី"ក" ចំនួនមួយច្បាប់ និងភាគី"ខ" ចំនួនមួយច្បាប់ ។

**ភាគី"ខ"**
**អភិបាលខេត្ត**
សរ ចំរុង

**ភាគី"ក"**
**ជ.ប្រធាននាយកប្រតិបត្តិ**
**នាយកសាខា**
មូ_សុផា